ការសម្ភាសរបស់បងស្រី ឡាញ់ ពៅ

កះអ្នកសម្ភាសគៃឈ្មោះរត្ន ស្រី ភាព
ខះអ្នកដែលគេនឹងបានសម្ភាសឡាញ់ ពៅ
<u>ការសង្ខេបជីវប្រវត្តិរបស់បងស្រីមានឈ្មោះថា ឡាញ់ ពៅ</u>

គាត់ជាអ្នកដែលបានខំសូរទ្រាំនៅក្នុងជីវិតគាត់តាំងពីតូចរហូតមកដល់គាត់នឹងមកដល់រាល់ថ្ងៃនឹងហើយគាត់នៅតែបានខំតសូរនៅជីវិតគាត់ណាស់ហើយយ៉ាងទៀតគាត់មិនបានសូរសប្បាយប៉ុន្មានទេគាត់នៅតែពិបាកនៅក្នុងជីវិតគាត់រាល់ថ្ងៃនឹងដែលតែគាត់នៅតែខំតសូរនៅក្នុងជីវិតគាត់មកដល់រាល់ថ្ងៃ។

កះចឹងជាដំបូងនាងខ្ញុំសុះរាប់សួរនាងខ្ញុំនឹងឈ្មោះរត្នស្រីភាពសុំអនុញ្ញាតសម្ភាសជីវប្រវត្តិរបស់បងបងស្រីនៅពេលដែលខ្ញុំនឹងធ្វើកាលសម្ភាសនឹងគឺធ្វើឡើងដោយសាលារៀនមួយដែលគេនឹងបានហៅថាសាលារៀb y u នៅអាមេរិច
ណាបងចាំដើម្បីថែក្សា ប្រវត្តិរបស់បងនឹងថែរក្សាជីវប្រវត្តិរបស់ជីដូនតារបស់បងសំរាបចង់ក្រងជីវិតមួយសំរាប់កូនចៅជំនាន់ក្រោយគេនឹងបានដឹងថាអ្នកេជំនាន់មុននឹងរស់នៅដោយរបៀនណាខ្លះគេពិបាកនៅក្នុងគេហើយដូចជាមួយជំនាន់ៗតសូរនៅក្នុងជីវិតពួកគេអីខ្លះនៅក្នុងជីវិតគេចឹងណាបងណា?
ខះចាំ!
កះចាំចឹងខ្ញុំសុំប្រាប់បងទិចនៅពេលដែលខ្ញុំបានោធ្វើកាលសម្ភាសនឹងគឺធ្វើនៅថ្ងៃទី១០ខែ០៥ឆ្នាំ២០១៨ណាបងណា?
ខះចាំ!
កះចឹងតើបងមានឈ្មោះអ្វីដែលបង?
ខះខ្ញុំឈ្មោះឡាញ់ ពៅ។
កះបងមានឈ្មោះហៅខាងក្រៅទេ?
ខះអត់មានទេខ្ញុំមានឈ្មោះហៅតែពីងនឹង។
កះបងមានឈ្មោះឡាញ់ ពៅចឹងនែបង?
ខះចាំ!
កះចាំចឹងមានន័យថាលោកឪពុករសប់នឹងមានឈ្មោះនាមក្រកូលថាឡាញ់ចឹងបានជាបងនឹងបានដាក់ឈ្មោះឡាញ់ពៅជាឈ្មោះរបស់បងចឹង?
ខះចាំ!
កះចាំចឹងតើបងអាចប្រាប់ខ្ញុំបានថាបងរាល់ថ្ងៃនឹងបងមានអាយុនឹងប៉ុន្មានដែលបង?
ខះខ្ញុំនឹងអាយុនឹង៣៦។
កះ៣៦ឆ្នាំចឹងហើយបងដែលបានចាំឆ្នាំកំណើតរបស់ខ្លួនហើយបានកើតនៅខែណាទេបង?
ខះកាលមុនឪគាត់នឹងបានកត់ទុកដែលនឹងតែឥឡូវនឹងខ្ញុំភ្លេចនៅណាទេ។
កះចាំ! ប៉ុន្តែបងអាចប្រាប់បានថា?
ខះឆ្នាំចរប៉ុន្តែកើតនៅថ្ងៃអាទិត្យ។
កះអ្នឆ្នាំចរបានកើតនៅថ្ងៃអាទិត្យនែ៎បងនែ៎?
ខះចាំ!
កះចាំចឹងបងអើយមិនមែនអ្នកស្រុកកំណើតនៅភ្នំពេញនឹងទេ?
ខះនៅស្រែនែ៎ ។
កះនៅខាងណាដែលបង?
ខះនៅព្រៃវែង។
កះអ្នកនៅព្រៃវែងគេបានហៅភូមិឃុំអីដែលបង?
ខះភូមិព្រៃកន្ទៀម ស្រុកពៀមរង ខេត្តព្រៃវែង។
កះចាំរៃវែងចឹងបងជាអ្នកខាងព្រៃវែងនែ៎បងនែ៎?
ខះចាំ!
កះចាំចឹងបងបានផ្លាក់មករស់នៅទីក្រុមភ្នំពេញនឹងអស់ប៉ុន្មានឆ្នាំហើយបង?

ខ:ទើបនឹងបានមកមួយឆ្នាំនឹង។
ក:ចឹងទើបបានផ្លាក់មកនៅនឹងបានតែមួយឆ្នាំ?
ខ:ចា៎!
ក:ចា៎!
ចឹងបងបានមកនៅនឹងគឺបងប្រើអាជីមុខរបរអីគេដែលបងហើយបានធ្វើការអីគេ?
ខ:កាលមុននឹងខ្ញុំនឹងបានធ្វើការនៅហាងស៊ុបនឹងហើយគេនឹងបានអោយខ្ញុំបានធ្វើកាក្រពេកក្រពុតទៅ។
ក:នឹងកាលចឹងបងបានធ្វើកាលអោយហាងស៊ុបនឹងគេបានអោយបងធ្វើអីបងរឿងមួយគេបានអោយបងនឹងបានធ្វើជាចុងភៅនឹង?
ខ:នឹងគេបានអោយខ្ញុំនឹងបានធ្វើប្រៃសាច់ហើយនឹងបានចាប់សាច់អោយគេនឹង។
ក:អូចា៎! តែឥឡូវនឹងបានឈឺពេកនែ៎?
ខ:ឈឺពេកនឹងបានខ្ញុំនឹងបានឈប់ធ្វើការ។
ក:ក្នុងខ្លួននឹងចេះតែយ៉ាងមិចដែលបង?
ខ:វាចេះតែហៀរៗ។
ក:អត់មានកំលាំងអីសោះម៉ងបង?
ខ:ចា៎!
ក:ចា៎!
ចឹងបងបានផ្លាក់មកនៅទីក្រុមភ្នំពេញនឹងទើននឹងបានតែមួយឆ្នាំទេមកនៅនឹងតែម្តងអត្តើមានទៅនៅណាផ្សេងពីណាទេបង?
ខ: អត់ទេ។
ក:ចា៎ចឹងតើបងមានបានស្គាល់ថាសង្គាត់អីសង្គាត់គេដែលអូនសូមនិយាយអោយបានលឿទិចមកអូន?
ក:ជាកូនស្រីគាត់ សង្គាត់ឬស្សីកែវ។
ក:សង្គាត់ឬស្សីកែវ ខណ្ឌរាជធានីភ្នំពេញនឹងអូន?
ក:ចា៎!
ក:ចឹងនៅនឹងគេបានហៅបឹងស្រឡាងបង?
ក:ចា៎!
ក:អូចឹងនៅនឹងគេបានហៅថាបេងស្រឡាងចឹងនែ៎?
ខ:ខ្ញុំអត់បានដឹងដែលនឹង។
ក:កូនបងនឹងគាត់បានមករៀននៅនឹងនែបងបានគាត់នឹងបានស្គាល់អីចឹងណាបង
ចឹងតើបងអាចប្រាប់ខ្ញុំបានទេថាបងប្អូនបង្កើតរបស់បងនេងតើមានប៉ុន្មាននាក់ដែលបង?
ខ:បងប្អូនខ្ញុំនឹងមនាប្រើននាក់ដែលនឹង៩នាក់នឹងនែ៎។
ក:អូចឹងបងបងប្អូនបងនឹងមានដល់ទៅ៩នាក់នឹង
អើយចឹងបងជាកូនទីប៉ុន្មានដែលបង?
ខ:កូនពៅគេ។
ក:កូនពៅគេនឹងអាយុ៣៦ឆ្នាំ?
ខ:ចា៎!
ក:
ចឹងមានន័យថាកូនបងគេនឹងគាត់មានអាយុនឹងជិត៤០ហើយនឹង៥០ហើយនឹងចឹងបង?
ខ:៥០ជាង។
ក:ចា៎!
ខ:បងគេនឹង៥០ជាងជិត៦០ហើយ។
ក:ចឹងពួកគាត់នឹងបាននៅរសើនៅទាំងអស់គ្នា?
ខ:នៅទាំងអស់នឹង។
ក:នៅទាំងអស់គ្នានឹង៩នាក់របស់បងប្អូនបង?
ខ:៩នាក់បងប្អូនខ្ញុំនឹងស្និតតែពិបាកអូនអើយ។

កះថ៉ាចឹងបងអាចប្រាប់ខ្ញុំទាំងបងប្អូន៩នាក់តើគាត់នឹងមានឈ្មោះអីដែលបងទីមួយនឹងឈ្មោះអីគេបង?
ខះបាន។
កះបងបានទី២!
ខះបងរាម!
កះថ៉ា!
ខះបងរេត បងរា បងរាត់ បងរឹត បងរាយ បងរេត
ខ្ញុំនឹងបងប្អូនខ្ញុំ៩នាក់នឹង។
កះថ៉ា!បងពៅថាចឹងសំរាប់បងផ្ទាល់ចឹងបងណាបងមានបងប្អូនបងដល់ទៅ៩នាក់ដូចជាបងជាកូនពៅគេចឹងតបងអាចចាំសាច់រឿងអ្វីខ្លះកាលនៅពីក្មេងដែលបងប្អូនរបស់បងៗដែលបាននាំបងអោយធ្វើការណាដូចជាបានណែននាំអីខ្លះធ្វើកាលនឹង?
ខះណែននាំធ្វើស្រែធ្វើអីនឹងមិនបានណែននាំធ្វើអីទេកាលនឹងតែស្លូនដក់នឹងមើលក្របីមើលគោមិនបានធ្វើអីទេខ្ញុំនឹងបានពិបាកជាងគេនឹងកាលនឹងទៅមើលក្របីទៅមើលគោចឹងទៅមានអុលភ្លានក្តាខ្ចងអីនឹងមកហូបអីណាចេះតែរកមកហូបទីណាកាលនឹងយើងនឹងវាអត់។
កះថ៉ាជិកទំពោងអីទៅកាលនឹង?
ខះមិនបានដើរជិកទំពោងទំពោងកាលនឹងនៅផ្ទះរាលចឹងរើសខ្ចង់អីចឹងក្តាមជាញាស្រីអីចឹងយកមកហូប។
កះថ៉ាដូចថាទីមើលគោផងទៅឆ្លៀតរកចឹងផងទៅ?
ខះនឹងហើយយើងនឹងអត់។
កះនឹងយើងនឹងកាលនឹងបងបានធ្វើចឹងដោយខ្លួនឯងឬក៏មានបងប្អូនបងកាលនឹងគាត់ជាអ្នកដែលបានប្រាប់អោងបានធ្វើ?
ខះខ្ញុំនឹងបានធ្វើដោយខ្លួនឯងនឹងតែម្តង។
កះដូចថាបងមានឆន្ទះដើម្បីរក?
ខះនឹងហើយខ្ញុំនឹងបាននៅពេងនៀកទៅទូលអុលផងរកក្តាមផងរកខ្ចង់ផងខ្ញុំនឹងបានរ៉ែតសំណាមផងកំសត់អស់ហើយបងអើយឆ្អែតអស់ហើយ។
កះថ៉ា! ចឹងជីវិតនឹងបានជូតជត់អស់ហើយនែ៎បងនែ៎?
ខះថ៉ា!
កះចឹងនៅពេលនឹងបងអាចមានអ្វីជាការងាដែលបងអាចបានធ្វើកាងារជាមួយដូចជាជួលចិត្តធ្វើកាងាររួមគ្នាទាំងបងប្អូនបង៩នាក់នឹងតែម៉ងណាមានពេលកាងារអីខ្លះបងអាចចាំបានទេបងធ្វើស្រែទៅច្រូវស្រូវ?
ខះធ្វើស្រែច្រូវស្រូវនឹងទាំងអស់គ្នាស្រូវនឹងធ្វើកាលនឹងទាំងអស់គ្នានឹង។
កះថ៉ានែ៎!
ខះហើយយើងនឹងបានចង់ក្របីនឹងចង់គោនឹងបានអោយស៊ីហើយខែច្រូវ។
កះថ៉ាៗ
ខះបើយប់នឹងដើរកក្រីអីនឹងកាត់យប់កាត់អាក្រៀមខ្ញុំដើរដាក់ប្រូដើរដាក់កៃ។
កះទៅម្នាក់ឯងបងអីបង?
ខះម្នាក់ឯង។
កះអូអត់បានខ្លាចគេនឹងបានធ្វើបាកអីបង?
ខះគ្មានអ្នកណាគេនឹងបាមធ្វើបានឱកទេក្មេងៗដើរមួយក្រនរដែលនឹង។
កះអឺចង់និយាយថាមិនមែនតែយើងនឹងម្នាក់ឯងនែ៎បងនែ៎?
ខះគឺនឹងបានដើរកពេញភូមិដូចជាម៉ារផ្ទះមួយនឹងម្នាក់ទៅម៉ារផ្ទះនឹងពីរបីម្នាក់ចឹងទៅ។
កះអឺថ៉ា!
ខះដល់ម៉ោង៣នឹងបាននាំគ្នានឹងទៅលីអស់ហើយ។
កះថ៉ាដាក់ជិតដែលបានសព៌ាទេបង?
ខះដែលបានតើ។
កះឃើញវានឹងបងបានខ្លាចវាទេបង?
ខះខ្លាចអីឃើញវាចឹងរ៉ែវានឹងអោយបានដាប់នឹង។

កៈអីនឹងបងឯងសំណាងហើយក្នុងពេលដែលបងបានឃើញសព់អីនឹងខ្ញុំនឹងបានទៅបាត់ខ្ញុំខ្លាច?
ខៈខ្ញុំនឹងបានរែសព់នឹងដល់ងាប់។
កៈអែចឹងមិនបានថាផ្លាន់អីនឹងបងរែវាអោយងាប់បងចឹងអោយតែបានដួលមកចឹងដឹងថាចប់ហើយនឹងចឹងតើបងមានបានចាំបានទេថាសព្វថ្ងៃនឹងតើបងប្អូនបងរស់នៅណាខ្លះទេបង?
ខៈនៅក្នុងភូមិទាំងអស់។
កៈមានតែបងមួយនឹងដែលបានមករស់នៅភ្នំពេញនឹងតែម្នាក់ឯង?
ខៈបងមួយនឹងគាតើបានទៅនៅកំពុងចាមបងនៀកបងនឹងបាននៅពេញនឹងមួយដែលនៅជាមួយនឹងខ្ញុំនឹង។
កៈចឹងមានន័យថាបងប្អូនទាំង៩នាក់នឹងមានតែបីនាក់នឹងទេដែលបានចាកចេញពីស្រុកកំណើត?
ខៈចាំ!
កៈដូចជាបងមួយនឹងបងស្រីបងមួយទៀត?
ខៈចាំ!
កៈនៅភ្នំពេញនឹងពីនាក់នៅខាងខេត្តកំពុងចាមនឹងពីនាក់អូម្នាក់?
ខៈឥឡូវនឹងទៅពីនាក់ទៀតហើយ។
កៈទៅកំពុងចាមទៀតបង?
ខៈចាំ!
កៈចឹងមានន័យថាអ្នកដែលនាមរស់នៅស្រុកកំណើតនឹងមានតែប៉ុន្មានទេ?
ខៈចាំបីបួនប្រាំនាក់។
កៈ ចាំបងមកនៅទីក្រុងភ្នំពេញនឹងប្រកបមុខរបរអ្វីដែរបង?
ខៈ លក់ទឹកអំពៅតែខ្ញុំមិនបានទៅទេតែប្តីខ្ញុំគាត់ទៅលក់ខ្ញុំឈឺពេក។
កៈ ចាំ!ចឹងបងផ្សេងៗទៀតគេមានមុខរបរអាជីកម្មគេរៀងៗខ្លួនហើយបង?
ខៈ ពិបាកដែរនឹងចែអើយគ្នាដើររកអន្លងដើររកឆក់ដើរលក់អីចឹងណាស់។
កៈ ដើរឆក់អីគេដើរឆក់ត្រីឆក់អីចឹងទៅបង?
ខៈ ចាំដើរឆក់ត្រីឆក់អន្លងអីទៅដើរលក់រាល់ថ្ងៃចឹងទៅ។
កៈ ចាំដើរលក់រាល់ថ្ងៃអីចឹងទៅបងណាស់?
ខៈ ចាំ!
កៈ
ចាំលក្ខណៈថាប្រើលជីវភាពសាម្ញាន់របស់យើងជាប្រជាជនក្រីក្រធម្មតារទៅហើយបើសិនជាអ្នកមានក៏គេមិនដើរធ្វើចឹងដែរចឹងសព្វថ្ងៃនឹងឪពុកម្តាយរបស់បងនៅរស់ទាំងអស់ស្អាបង?
ខៈ ស្លាប់អស់ហើយឪពុកម្តាយបង។
កៈ អូរឪពុកម្តាយរបស់បងស្លាប់តាំងពីជំនាន់ណាមកបង?
ខៈ ឪខ្ញុំស្លាប់តាំងពីខ្ញុំនៅតូចមកណាស់។
កៈ អរចាំ!
ខៈ
បើម្តាយខ្ញុំគាត់ស្លាប់តាំងពីអាយុប្រហែលជាខ្ញុំមានអាអូនហើយប្រហែលជាបួនប្រាំឆ្នាំហើយ។
កៈ ចាំឪពុកបងស្លាប់តាំងពីអាយុប៉ុន្មានបង?
ខៈ ខ្ញុំ។
កៈ តាំងពីអាយុ៥ឆ្នាំណាស់។
កៈ អត់ទេបងលោកឪពុករបស់បងស្លាប់តាំងពីអាយុប៉ុន្មានបង?
ខៈ ឪខ្ញុំគាត់អាយុ៤០ឆ្នាំជាងនឹង។
កៈ គាត់អាយុ៤០ឆ្នាំជាងនឹងគាត់ស្លាប់ដោយសារជំងឺអីបង?
ខៈ
ប្អូនគាត់កាប់ប្អូនបង្កើតគាត់ខឹងព្រោះបងថ្លៃណាស់ដល់គាត់រើលមីប្អូនថ្លៃនឹងចេញទៅគាត់ចូលទៅប្អូនកាប់ស្លាប់ទៅ។
កៈ ចង់និយាយថាគាត់ការពារគាត់មិនមែន?
ខៈ គាត់ចង់មិនអោយឈ្លួសគ្នា។

ក៖ ចាំគាត់ចូលទៅចំកណ្តាលទៅក៏កាប់គាត់ទៅ?
ខ៖ ចាំ!
ក៖ ចាំអូយណាស់ហើយត្រូវកន្លែងណាបង?
ខ៖ នេះត្រូវនេះហូលឈាមរហូត។
ក៖
ចាំអរបងហើយៗចឹងគាត់ស្លាប់តាំងពីជំនាន់បងនៅពីក្មេងមានអាយុ៥ឆ្នាំមកហើយបង?
ខ៖
តាំងពីខ្ញុំមានអាយុ៥ឆ្នាំនឹងខ្ញុំនៅចាំតារថាគាត់ហៅខ្ញុំមកអប់ចឹងគាត់ក៏ដាច់ខ្យល់ស្លាប់ទៅ។
ក៖ អរត្រូវហើយនឹងបងនែ?
ខ៖ ចាំ!
ក៖ហើយអើយតើបងមានបងមានចាំទេបងកាលនឹងលោកឪពុកបងឈ្មោះអីដែលបង?
ខ៖ឈ្មោះលាញ់។
ក៖ចាំ!ចឹងអ្នកម្តាយរបស់បងឈ្មោះអីគេដែលបង?
ខ៖យាយប៊ូ។
ក៖ចឹងតើគាត់នឹងបានស្លាប់នឹងអាយុប៉ុន្មានដែលបង?
ខ៖៧២!
ក៖ទើនឹងបានស្លាប់ឥឡូវនឹងដែលបង?
ខ៖គាត់នឹងបានស្លាប់បាន៥ឆ្នាំហើយ។
ក៖ប៉ុន្តែពេលនឹងបានមានក្មួនចៅនឹងបានធំធាត់ហើយបងនែ?
ខ៖ធំៗហើយអានេះរៀងធំហើយ។
ក៖ចាំ!
ខ៖គាត់នឹងបានស្លាប់នឹងបានប្រាំឆ្នាំហើយ បានគាត់នឹងបានស្លាប់។
ក៖ចាំ!ចឹងតើសំរាប់បងផ្តាល់តើបងមានចាំថាគាត់នឹងបានកើតនៅឆ្នាំណាខែណាទេបង?
ខ៖អត់ចាំទេ។
ក៖អត់ចាំចុះបើសិនជាអាចឆ្នាំខ្មែរ ដូចជា ជូត ឆ្លូវ ខាល
ថោះតើអ្នកមីងបានចាំទេ?
ខ៖បើឪខ្ញុំភ្លេចតែម៉ងបើម៉ែគាត់នឹងឆ្នាំរោង។
ក៖ឆ្នាំរោងនែ៎បងនែ៎ចាំគាត់ជាអ្នកស្រុកកំណើតនឹងនៅណាដែលបង?
ខ៖ហើយឪខ្ញុំនឹងនៅខាងព្រៃម្តេងខេត្តព្រៃវែងដែលហើយម៉ែខ្ញុំនឹងនៅព្រែកពេទ។
ក៖ព្រែកពេទនឹងនៅខាងព្រៃវែងដែលខុសតែភូមិគ្នានែ៎បងនែ?
ខ៖ចាំ!
ក៖មួយខាងព្រៃវែងនឹងចំមួយខាងព្រែកពេទនឹង?
ខ៖ខាងព្រែកម្តេង។
ក៖អូរព្រែកម្តេងនែ៎បងនែ៎ចឹងតើបងចាំថាកាលលោកឪអ្នកម្តាយកាលគាត់នឹងមិនបានទាន់ចែកថានទៅនឹងដូចជាគាត់នឹងបានប្រកាមុនបបរអីចិញ្ចឹមបងដែលបង?
ខ៖អើយអ្នកម្តាយខ្ញុំនឹងគាត់បានពិបាកណាស់ចែអើយធ្វើស្រែនឹងក៏មិនបានគាត់ដើរតែដើរដាំអាក្រដួចបាយអោយយើងនឹងហូបនឹងដូចហាលដាំបាយហើយនឹងបានលាយបាយអោយយើងនឹងបានហូបនឹង។
ក៖អឺ!
ខ៖ហើយគ្រាន់នឹងបានអោយយើងនឹងបានហូបទៅអោយតែឆ្អែតទៅៗ។
ក៖ចាំដូចជាគាត់នឹងមិនចង់ឃើញកូនគាតើនឹងបានអត់ខ្លៀងនែបងនែ?
ខ៖ចាំ!
ក៖ចឹងកាលនឹងគាត់បីងដាំដើមក្រដួចនឹងបង?
ខ៖ដាំដើមក្រដួចដែលយើងនឹងបានដាំនឹងខ្ញុំជិនហាលដាក់បាយពីរកំប៉ុងទៅយើងអោយបានច្រើន។

កះកាលនឹងមានសរជាតិនឹងមិចដែលបង?
ខះមិនអីទេគ្រាប់តែវារៀនខ្សោះទិចនឹង។
កះតែបើគ្រាប់តែវានឹងអោយណឹងពោះដូចបាយដែលបង?
ខះចំាណឹងពោះដូចបាយ។
កះជិទសំបរនឹងទៅ?
ខះនឹងហើយជិទសំបក។
កះហើយនឹងបានដាក់ហាល?
ខះជិទស្តើងៗនឹងបានដាក់ហាល។
កះដល់ពេលចឹងគេបានហៅថាផ្លែក្រដូចនែបងនែ?
ខះចំា!
កះចឹងយកវានឹងលាយជាមួយនឹងបាយហើយហាលវានឹងអោយបានក្រៀបដូចស្លឹកឈើក្រោបៗនឹងទៅយកមកលាយជាមួយនឹងបាយ?
ខះចំា!
កះអូចំាចឹងតើប
ងអាចប្រាប់ខ្លុំបន្តែមទិចទៀតបានទេថាលោកឪពុកអ្នកម្តាយរបស់បងណាទើចំពោះបងផ្តាល់បងគិតថាពួកគាត់នឹងជាមនុស្សបែកណាដែល?
ខះគាត់នឹងល្អណាស់ចែ។
កះគាត់នឹងកាចទេបង?
ខះគាត់នឹងកាចទេគាត់នឹងស្លូត។
កះចំា!
ខះឪគាត់នឹងស្លូតម៉ែខ្លុំនឹងក៏គាត់នឹងស្លូតណាស់។
កះចំា!ចឹងមានអនុស្សាវរីយ៍ភាពជូតជត់ជាមួយនឹងឪពុកម្តាយបងទេ?
ខះមានដែលកាលនោះគាត់នឹងបានហៅអោយដក់ស្តូរគាត់ចឹងគាត់ជោកយើងចឹងកាលគាត់នឹងបានស្លាប់ទៅនឹងអាណោតអាថោមគាត់ដែល។
កះចំា!គាត់នឹងបានរស់នៅជាមួយនឹងបងបានយូរឆ្នាំដែលអ្នកម្តាយរបស់បងចឹង?
ខះគាត់នឹងបានមេម៉ាយនឹងជាប់៣០ឆ្នាំហើយនឹង។
កះជិវិតគាត់នឹងបានលំបាកអីខ្លះទេបងពេលដែលលោកឪពុកបងបានចែកចានទៅអ្នកម្តាយបងម្តាយបងដែលបានរស់នៅជាមួយនឹងគាត់?
ខះលំបាកដែលគាត់មិនបានដឹងធ្វើមិចគាត់បានលើសឈាមផងហើយកាលនឹងគាត់បានឈាមផងខ្លុំបណ្តើរម្តាយខ្លួនឹងមិនបានផុតស្រែទេម៉ែខ្លុំមិនបានដែលស្គាល់ស្រែផងនឹងទល់តែគាត់នឹងបានស្លាប់ផងនឹងខ្លុំបានឌុបគាត់បានទៅស្រែគាត់មិនបានស្គាល់ស្រែគាត់ផងនឹង។
កះមិចចឹងបង?
ខះពីព្រោះគាត់នឹងបានលែងទៅស្រែនឹងជាប់៣០ឆ្នាំហើយនឹងកាលនឹងខ្លុំនឹងបានឈប់អោយគាត់នឹងទៅហើយនឹងខ្លួំបានធំពីងនេះខ្លុំមើលក្របីខ្លុំស្តួនដក់ខ្លុំឈប់អោយគាត់នឹងទៅស្រែ។
កះដោយសារឃើញគាត់នឹងចាស់ពេក?
ខះគាត់នឹងពិបាកគាត់លើសឈាមផង។
កះចំាហើយបងបងប្អូនបងដ៏ទៃទៀតគេអត់មានជួយគាត់ទេបងនែ?
ខះគេបានជួយខ្លះដែលតែគេនឹងបានមានប្តីហើយនឹងប្រពន្ធទៅគេនឹងបានរកស៊ីរបស់គេទៅយើងនៅយើងបងពីរ
បីនាក់នឹងខ្លុំនឹងបានរកស៊ីជួយគាត់ហើយខ្លុំនឹងបានដើរស៊ីសួនគេរកលុយនឹងអោយគាត់ដឹងទៅស៊ីសួនគេបានមួយថ្ងៃបាន៣០០០ជាង២៥០០នឹងកាលនឹង។
កះចំា! ស៊ីសួននឹងរយៈអស់ប៉ុន្មានឆ្នាំដែលកាលនឹង?
ខះកាលនឹងខ្លុំដើរស៊ីសួនគេនឹងបានតែពីរ បីឆ្នាំ។
កះអ្នសំរាប់តែដើរដក់ស្តួនគេនឹងបង?
ខះចំា!
កះហើយនៅក្មេងសោះកាលនឹងបង?
ខះអឺខ្លុំដើរដក់ស្តួនគេបានតើកាលនឹង។
កះចំា!

ខ:គេនឹងមិនបានចឹងយកខ្ញុំផងកាលនឹងគេនឹងបានឃើញយើងនឹងច្រណាប់បានគេនឹងយកយើង។
ក:ដោយសារឃើញយើងនឹងបានតូចតែមៀតតែយើងនឹងបានធ្វើកាលនឹងលឿងនែបងនែ?
ខ:ដក់រាប់ភ្លូននឹងរាប់ភ្លូននឹងគេទៅយើងនឹងបានមុនគេយើងនឹងបានឡើងមុនគេទៅ។
ក:អើយថា!
ខ:ដក់មួយភ្លូននឹងទៅ។
ក:មួយភ្លូននឹងបាន៥០ក្រដាបនែបង?
ខ:៤០!
ក:៤០ក្រដាប?
ខ:ថា!
ក:នឹងស្លូនមិចបង?
ខ:អោយនឹងស្លូនយើងនឹងបានស្លូនអស់ម៉ារអស់ទៅស្លូននឹងយើងដក់គេរាប់ក្រដាបរាប់ភ្លូន។
ក:ថារាប់ភ្លូនបើច្រូវរិញគេបានកំណាត់ក្រដាបដែលបងនែ?
ខ:ច្រូវកាលនឹងគេច្រូវថ្ងៃកាលនឹងមើលកាលនឹងច្រូវស្រុកខ្ញុំនេះគេបានច្រូវរាប់ក្រដាបខ្ញុំច្រូវបាន៥ ៦ រយ។
ក:អូបាន៥ ៦ រយក្រដាបអរមិនមែនទេ៥ ៦ រយដែ?
ខ:៥ ៦ រយក្រដាប។
ក:អូច្រើនបងនែ?
ខ:អូប្រឹងមែនទែនស្រូវនឹងបានព្រួយ។
ក:អើយប្រឹងនឹងយ៉ាងលេងនិយាយនែបងនែអោមគិតតែពីអោមធ្វើការនឹងតែម៉ង?
ខ:ប្រឹងៗចេះតែប្រឹង ប្រឹងនឹងវេលាថ្ងៃនឹងតែម៉ងនឹង។
ក:អីហើយបានច្រើនទេបងកាលនឹង?
ខ:មួយថ្ងៃនឹងបាន៣ ៤មុ៉ីនដែលកាលនឹង។
ក:តែស្រហារនែបងតែម៉ងបាននឹងបានអស់ដៃអស់ជើងមកផ្ទះវិញ?
ខ:អស់ដៃអស់រលិង។
ក:សឹងតែដើរមកផ្ទះវិញនឹងមិនបានចឹងដល់នែបងនែ?
ខ:ថា!
ក:អាពេលធ្វើនឹងគិតថាអោយតែបាននែបងនែដល់ពេលស្រាប់?
ខ:អាណិតម៉ែ។
ក:អណិតម៉ែហើយបងប្អូននឹងបានជួយបានខ្លះដែលនែបងនែតែអត់បានគ្រាប់គ្រាន់នែបងនែ?
ខ:អត់គ្រាប់គ្រាន់ទេ។
ក:ចឹងបងធ្លាប់ដែលមានចាមសាច់រឿងអីខ្លះអំពីពួកគាត់កាលនៅពីក្មេងទេបងជាមួលហេតុអីបានគាត់នឹងបានជួបគ្នាជាប្តីប្រពន្ធគាត់ដែលបានដំណើរចាស់រឿងនឹងខ្លះទេបង?
ខ:គាត់មិនដែកបាននិយាយផងគាត់គ្រាន់គាត់ថាអើយឪឯងជួបអញ្ចឹមកស្រលាញ់អញ្ចឹងៅនឹងតែម្តងគាត់និយាយតែពីងនឹង។
ក:ហើយភាពជួតជត់ប្តីប្រពន្ធគាត់នឹងកំសត់កំក្រមអីនឹងគាត់មានដែលបាននិយាយទេនែបងនែ?
ខ:គាត់នឹងអត់ដែលបាននិយាយអីទេគាត់នឹងបានពិបាកគាំងពីដើមមកគាត់មិនដែលបាននិយាយផង។
ក:ថា!សំរាប់បងផ្ទាល់តើបងមានចាមឈ្លោះលោកតាលោកយាយអីទេបងចាងអ្នកម្តាយហើយនឹងខាងលោកឪពុកអី?
ខ:ចាំតើ!
ក:គាត់នឹងឈ្លោះអីខ្លះបង?
ខ:តារែមយាយរាំង។
ក:នឹងខាងឪពុកខាងអ្នកម្តាយ?

ខ:ខាងម្តាយ។
ក:ចា!
ខ:តាវ៉ាន់យាយរ៉ែម។
ក:នឹងខាងម្តាយ?
ខ:ឪពុក!
ក:តាវ៉ាន់យាយរ៉ែមនឹងខាងឪពុក?
ខ:តាវ៉ាន់យាយរ៉ែមនឹងខាងម្តាយ។
ក:ចា!
ខ:តាអឹមយាយវ៉ាន់ដែលខាងឪពុក។
ក:មួយតាវ៉ាន់យាយរ៉ែមមួយទៀតតាអឹមជាមួយអីគេ?
ខ:យាយវ៉ាន់។
ក:យាយវ៉ាន់ដែលនឹងខាងម្តាយ?
ខ:ខាងឪ។
ក:អូននឹងខាងឪពុកចា?
ខ:ខ្ញុំមិនដែលបានឃើញមុខទេ។
ក:ឃើញលីតែឈ្មោះនែ?
ខ:គាត់នឹងបានប្រាប់។
ក:អូបើមុខមាត់នឹងអត់ដែលបានឃើញទេភាពកំសត់កំក្រមនឹងជាមួយនឹងគាត់នឹងក៏អត់មានឃើញដែល?
ខ:អត់ទេ។
ក:គាត់នឹងបានស្លាប់យូរនែបងនែ?
ខ:គាត់នឹងបានស្លាប់តាំងជំនាន់អាពតមក។
ក:មានបានចាំម្តាយបងគាត់បានប្រាប់ជំនាន់អាពតនឹងគាត់នឹងបានស្លាប់មិចដែលបង?
ខ:មិនដឹងទេថាគេនឹងបានយកទៅរ៉ែចោលអីនឹង។
ក:លណ្ហះថាគេនឹងយកគាត់នឹងទៅរ៉ែចោលអីចឹងបងនែតែលីតែគាត់នឹងបានថាយើងមិនបានដឹងពិតប្រាកដដែលចឹងនែបងនែ?
ខ:មិនដែលស្គាល់គាស្គាល់យាយផងនឹង។
ក:ម្តាយបងអីមានដែលបានប្រាប់ជីវិតគាត់នៅអាពតដែលអី?
ខ:ប្រាប់ទីថាគាត់នឹងបានរត់ទៅគេបានបាញ់គេអីធ្វើបាកក្លួនកាលគាត់នឹងបានពោះធំបងខ្ញុំរត់តែពោះធំមកដល់ពេញនឹងគេបាននាំទៅវិញទៀតកាលជំនាន់ខ្ញុំនឹងបានកើតគេនឹងបានបែកអាពតហើយ។
ក:ចា!
ខ:គេបានបែកអាពតនឹងគេនៅ។
ក:ភាពកំសត់កំក្រមនែបងនែចាចឹងចំពោះក្រុមក្លួសារបងផ្សេងៗទៀតបងណាតើបងអាចប្រាប់ខ្ញុំបានទេថាបងប្អូនរបស់បងឪពុកម្តាយរបស់បងទាំងអស់គ្នាតើពួកគាត់នឹងនៅខេត្តព្រៃវែងទាំងអស់គ្នាម៉ងនែបងនែ?
ខ:ចា!
ក:ចា!ចឹងតើបងមានសាច់ញាតដ៏ទៃទៀតដែលនៅក្រៅប្រទេសដែលទេបង?
ខ:អត់មានទេ។
ក:ត្រឹមថៃ វៀតណាម អាមេរិចអីនឹងមានទេបង?
ខ:អត់មានទេ។
ក:អត់ទេបងចាទាន់ទាងនឹងបញ្ហានឹងខ្សែជីវិតអាពិពាហ៍ពាហ៍របស់បងផ្តាល់តែម្តងណាបងតើស្វាយមីបងនឹងមានឈ្មោះអៅដែលបង?
ខ:ឈ្មោះភៀម បួន។
ក:ភៀង បួននែចាចឹងអើយបានបានរៀងការនឹងតាំងពីឆ្នាំណាដែលបង?
ខ:នឹងឆ្នាំណាភ្លេចហើយ។
ក:ចុះកូនបង បងអាយុប៉ុន្មានហើយបងសព្វថ្ងៃនឹង?
ខ:១២ឆ្នាំហើយ។
ក:១២ឆ្នាំចឹងអើយអូនបានបានកើតនឹងតាំងពីឆ្នាំណាមកអូន
អូនមានបានចាំឆ្នាំខែកើតរបស់អូនទេអូន?

គះអត់ផងៗ
កះចុះសាលចូលរៀននោះគេបានសួរអូនឯងនឹងបានកើតនៅឆ្នាំណា?
ខះអេឆ្នាំ ចរ។
កះឆ្នាំចរបើសិនជាគាត់នឹងអាយុ១២ឆ្នាំ១៨ណាបងៗ១២ដកនឹង៨ចឹងបងនឹងបានរៀនការនឹងតាំងពីឆ្នាំ១៦អេអត់ទេ២០០៦ណាបងចឹង២០០៦ ២០០៧ ២០០៨ ២០០៩ ២០១០
២០១១ ២០១២ ២០១៣ ២០១៤ ២០១៥ ២០១៦ ០២០១៧
២០១៨ចឹងមានន័យថាបងនឹងបានរៀបការនឹងតាំងពីឆ្នាំ២០០៦ហើយតើបងដែលមានចោលពោះអៅខ្លះទេកាលនឹងបង?
ខះខ្ញុំនឹងបានចោលនឹងមួយឆ្នាំ។
កះចឹងនឹងបងបានការនឹងតាំងពីឆ្នាំ២០០៦បងមិមែនបងការឆ្នាំ២០១៦ទេបង?
ខះចំ
កះចំរហូតដល់ឆ្នាំ២០១៨នឹងកូនបងនឹងអាយុ១២ឆ្នាំហើយបងបានចោលពោះនឹងមួយឆ្នាំណា?
ខះចំ!
កះចំ
ចឹងអើយបងមានចាំថាអាពិពាហពាហ៍របស់បងនឹងត្រូវបានលោកឪពុកអ្នកម្តាយរបស់នឹងជាអ្នកដែលបានរៀបចំអោយណាបង?
ខះម៉ែខ្ញុំឪខ្ញុំនឹងបានស្លាប់។
កះចំប៉ុន្តែម្តាយហើយនឹងបងប្អូននឹងជាអ្នកដែលបានរៀបចំអោយ?
ខះបងៗរៀបចំអោយ។
កះកាលនឹងបងមានចាំថាអាពិពាហ៍ពាហ៍របស់បងនឹងរៀបចំឡើងមកនឹងបានទទួលជំនួនទឹកដោះនឹងបានប៉ុន្មានដែលបង?
ខះអូកាលនឹងថោកនឹង។
កះប៉ុន្មានដែលបង?
ខះបានតែបីដីមាសនឹង។
កះចំបើ២០០៦បីដីមាសនឹងក៏រៀងគ្រាសមដែលណាបងមាសនៅឡើងថ្លៃចំងតើបងអាចប្រាប់ខ្ញុំបានទេដូចថាតើបងបានជួបជាមួយនឹងស្វាយមីរបស់នឹងជួបនៅកន្លែងណាកន្លែងធ្វើការឬមួយក៏អ្នកភូមិរស់នៅជាមួយនឹងគ្នាទេ?
ខះខ្ញុំមិនដែលបានជួបគ្នាទេ។
កះមិនចឹងបងបានស្គាល់គ្នានឹងជាប្តីនឹងជាប្រពន្ធ?
ខះអរចាស់ៗគេនឹងបានដុំតើប្តីខ្ញុំនឹងគាត់ទៅនៅថៃខ្ញុំនឹងបាននៅធ្វើនៅពេញនឹងខ្ញុំបានមកធ្វើសំណាងអីនឹងជាមួយម៉ែមានប្តីនឹងគេបានស៊ីស្លួនកាលនឹងខ្ញុំនឹងបានស៊ីស្លារនឹងតែម្នាក់ឯងតើ។
កះកាលនឹងមកស្តីនឹងកាលនឹងម៉ែឪនឹងជាអ្នកមកស្តីនឹងបងបានញ៉ាំស្លារម្នាក់ឯង?
ខះចំ!
កះជាមួយនឹងអារមួយកំម្លេចឹងបង?
ខះចំ!
កះ
ហើយខាងណោះនឹងគេបានញ៉ាំស្លារខាងគេនឹងជាមួយនឹងអារមួយកំម្លេដែលបងនែ?
ខះគេនឹងបាននៅថៃនឹង។
កះដល់ពេលគាត់នឹងបានមកបានបងនឹងរៀបការជាមួយនឹងគាត់បង?
ខះមកនៅថៃនឹងគេនឹងបានមកលេងចឹងទៅគេនឹងបានមួយខែបានគេនឹងបានការ។
កះបងអត់ខ្លាងគេនឹងអត់មកទេបង?
ខះចុះម៉ែឪគេនឹងបានថាចឹងហើយអូខាងស្រុកនឹងគេបានប្រកាន់ថាយើងនឹងយកប្តីនឹងមុនគេ គេអោយយើងនឹងបានសងបណ្តាការគេ
ដូចខាងគេនឹងបានយកប្រពន្ធមុនយើងឪគេនឹងបានសងខាងយើង។

កៈគេនឹងសងខាងយើង?
ខៈចឹងបានសមខាងយើងនឹង។
កៈចឹងបងបានការពារប្រពៃណីខ្មែរយើង?
ខៈចា៎!
កៈកុំអោយមានអ្នកនាពេលយើងទទួលនឹងបានស៊ីស្លារម្ហូររបស់គេទទួលពាក្យជាមួយនគេចឹងណា?
ខៈចា៎!
កៈចា៎បងនែចាចឹងអើយសំរាប់បងដែលបានទាក់ទងនឹងការទទួលជាមួយនឹងស្វាយមីជាប្តីប្រពន្ធនឹងតើបងបានកូបនឹងប៉ុន្មានដែលបង?
ខៈកូនពីនឹង។
កៈកូនពីនឹងសប្រុសមួយហើយនឹងស្រីមួយនឹងបងនែ?
ខៈចា៎!
កៈចា៎មានបញ្ហាខ្លះនៅក្នុងជីវិតនឹងទេបងបញ្ហាជាឧបគ្គសទេពេលបងនឹងបានការហើយ?
ខៈអីពិបាកណាស់វេនា។
កៈមិចដែលបង?
ខៈពេលកូនខ្ញុំនឹងបានកើតមកហើយទៅសួនទីដក់ចឹងយកគ្នានឹងទៅតាមផងអី។
កៈចា៎!
ខៈយកគ្នានឹងទៅលូនកាត់ចេកកាត់អីឈាមមាត់ឈាមមុខអស់ហើយ។
កៈអូ!
ខៈពិបាកណាស់ប្រហែលស្រកខែស្លូននឹង។
កៈប្តីនឹងអត់បានជួយខ្លះបងនែ?
ខៈប្តីនឹងបានជួយដែលគ្នានៅចូលរសហើយនឹងស្លូនចឹងទៅមានពេលណាមើលកូនមើលចៅ។
កៈចា៎ដោយសារតែមានជីវភាពតាមតឹមងរៀងខ្លួនៗណានែ?
ខៈចា៎!
កៈចា៎!
ចឹងអើយតើសំរាប់បងណាបងមានចេះប្រើភាសាខ្មែរបានល្អខ្លះទេបងធ្លាប់បានរៀបសូត្រខ្លះទេ?
ខៈខ្ញុំពីមុននឹងខ្ញុំធ្លាប់បានរៀនដែលតែឥឡូវនឹងខ្ញុំនឹងបានភ្លេចអស់ហើយខ្ញុំនឹងបានឈប់តាំងពីយូរហើយខ្ញុំខាងមើលហើយថាសេរសដែលនឹង។
កៈបងខាងរៀននឹងតែកាលពីមុននឹងបងបានរៀនជាបានត្រឹមថ្នាក់នឹងទីប៉ុន្មានដែលបង?
ខៈខ្ញុំនឹងបានរៀនកាលនឹងបានតែថ្នាក់ទៅ៤។
កៈចឹងអើយ!
ខៈចឹងខ្ញុំមិនបានមើលរូចទេ។
កៈចា៎អត់ទេបងអោយតែបងនឹងបានពាក្យថាបានរៀនណាបងណាចា៎ចឹងតើបងអាចចេះភាសាប្រទេសអីផ្សេងៗភាសាខ្មែរនឹងអីល្អរបងនឹងបងនឹងបានទៅធ្វើការជាមួយនឹងជនជាតិចិនភាសាចិនអើយកីអូអើយបងនឹងបានធ្វើការជាមួយនឹងជនជាតិថៃអីនឹងយើងនឹងបានចេះថៃអីនឹងបងទៅវៀតណាមយើងនឹងអាចចេះវៀតណាមអីចឹងណាបងយើងនឹងបានត្រូវការទំនាក់ទំនងជាមួយនឹងការកសុីនឹងចឹងតើបងមានការចេះភាសាប្រទេសនឹងអីទេ?
ខៈអត់មានទេ។
កៈអត់មានទេនែបងនែ?
គៈចេះថៃនឹងបានទិចៗ។
កៈអូបងបានចេះថៃនឹងបានទិចចឹងបងនឹងបានធ្លាប់បានទៅថៃបង?
ខៈខ្ញុំនឹងបានទិញម្ហូបអីនឹងបានទិចនឹង។
កជាមូលហេតុអីបានបងចេះថៃនឹងស្វាយមីបងគាត់ជាអ្នកដែលបានប្រៀងបង?
ខៈទេគេនឹងបានប្រាប់ទិញអង្ករអីនឹងណាទិញអង្ករទិញម្ហូបនឹង។

កៈអង្គរនឹងគេបានថាមិចបងភាសាថៃនឹង?
ខៈអៅសាន។
កៈអៅសានថាចឹងបងបានធ្លាប់ទៅនៅប្រទេសថៃដែល?
ខៈនៅថៃនឹងបានបួនខែជាងនៅបានទិចកាលនឹង។
កៈទៅកាលនឹងធ្វើអីកាលនឹងបង?
ខៈទៅនឹងធ្វើសំណង់។
កៈទៅធ្វើសំណង់នឹងជានឹងស្វាយមីបងនែ?
ខៈថ៎ា!
កៈចឹងសូមបងអាចប្រាប់ខ្ញុំអំពីខ្សែរជីវិតនៅពេលដែលបងនៅតូចរហូតដល់ធំណាបងតើបងបានរៀននៅថ្នាក់ទីប៉ុន្មាននឹងទីបួនចឹងបងនែ?
ខៈថ៎ា!
កៈបងមានឈ្មោះសាលាបឋមសិក្សាឬមួយសាលបងនឹងមានឈ្មោះអីដឹលបង?
ខៈសាលាអីគេមីអូនណា។
កៈសាលភូមិចាន់។
កៈនៅខេត្តតាកែវនឹងអូនៅខេត្តព្រៃវែង?
ខៈព្រៃវែង។
កៈព្រៃវែងនឹងបងថាចឹងអើយតើបងមានចាំឈ្មោះសាលនឹងបានច្បាស់ហើយអំពីសាលាអីគេនឹងអូន?
ខៈសាលាបឋមសិក្សាភូមិចាន់។
កៈសាលាភូមិចាន់?
កៈថ៎ា!
កៈសាលាបឋមសិក្សាភូមិចាន់ចឹងនែបង?
កៈថ៎ា!
កៈចឹងអើយតើកាលនឹងដូចជាកាលនឹង
បងបានរៀនត្រឹមថ្នាក់ទីបួននឹងតើបងដែលមានមិត្តភក្តិជិតស្និតជាបងនាក់ណាទេបង?
ខៈមានតើឥឡូវនឹងគេនឹងបានបែនគ្នានឹងអស់ហើយឆ្ងាញណាស់ហើយ។
កៈថ៎ា
ខៈដើរគេដើរកស៊ីនៅស្រុកថៃស្រុកអីនឹងអស់ហើយឥឡូវនឹង?
កៈថ៎ា!ដូចជាគេនឹងបានទៅនឹងដើម្បីជីភាពគេនឹងដែលណាបងនែកាលនៅពីរក្មេងមានអនុស្សាវរីយ៍អីគេខ្លះចង់ចាំសាចៀរឿងអីគេខ្លះកាលនឹងជាមួយនឹងពួកម៉ាក់បងអីដើរលេងជាមួយនឹងគ្នាអីនឹងមានទេបង?
ខៈមានតើយើងនឹងបានស្រលាញ់គ្នាចឹងទៅយើងទិញអីមកចឹងយើងនឹងចែកគ្នានឹងហូបមាន១០០អីកាលនឹងមានតែ៥កាស។
កៈអឺ!
ខៈចេះតែទិញនឹងដែកគ្នានឹងហូប។
កៈថ៎ា
ខៈស្រឡាញ់គ្នាណាស់កាលនឹងនោះឥឡូវគេនឹងមានៗអស់ហើយឯងក្រជាងគេគេមិនបានរាប់រកយើងទេឥឡូវនឹងយើងទេ។
កៈប៉ុន្តែបើយើងនឹងបានទៅជួបគេចឹងតើគេនឹងនៅតែនិយាយជាមួយនឹងយើងតើបង?
ខៈគេនឹងនិយាយរកប៉ុន្តែគេនឹងមិនបានរាប់រកយើងទេ។
កៈគេនឹងបានចុងមាត់ចុងកយើងនែបងនែបងបានធ្លាប់ស៊ីឈ្នួនដក់ស្លួនគេដែលបងនែ?
ខៈអូខ្ញុំនឹងបានឆ្អែតណាស់ហើយ។
កៈបន្តពីស៊ីឈ្នួនដក់ស្លួននឹងអោយគេនឹងតើបងធ្លាប់មានដែលបានធ្វើអីទៀតទេបងក្នុងជីវិតបងផ្ទាល់របស់បងសព្វថ្ងៃនឹង?
ខៈខ្ញុំនឹងបានធ្វើជាសំណង់ខ្ញុំនឹងបានយួរកំបោរអីអោយគេនឹង។
កៈអឺ!
ខៈខ្ញុំនឹងបានធ្វើសំនាង់នឹងបានបី បួនឆ្នាំដែលនឹងមកធ្វើនៅប៉ុស្តិ៍លេង៥។

កៈអូបងបានធ្វើនៅក្នុងស្ថាយន៍ទូរទស្សន៍លេងប្រាំនឹងបងហើយបងបានធ្វើនឹងបាន៣ ៤ឆ្នាំដែល?
ខៈចាំ!
កៈចាំចឹងអើយមានអីទៀតទេបងក្រៅពីនឹងមានធ្វើម្ហូបអាហារអីបង?
ខៈខ្ញុំនឹងទើបតែនឹងបានធ្វើឥឡូវនឹងធ្វើនៅកន្លែងហាងសាច់។
កៈចាំចឹងក្នុងមួយជីវិតបងនឹងកើតបងមានការផ្លាក់ប្តូរអីខ្លះទេបង?
ខៈមានផ្លាប់អីខ្ញុំនៅតែពិបាកចឹងយើងគាំងមានប្តីនឹងខ្ញុំដើរធ្វើទើបតែខ្ញុំនឹងបានមកធ្វើនៅហាងស៊ុបនឹង៕
កៈអើយចាំ!
ខៈហើយខ្ញុំនឹងបានធ្វើការនៅសំណង់នៅថៃនឹងពីងនឹង។
កៈនឹងជាការងារដេលបានផ្លាប់នឹងបានទទួលនៅកាលងារបញ្ហានៅក្នុងជីវិតរបស់បងចាំចឹងតើសំរាប់បងផ្តាល់តាំអពីតូចរហូតដល់សព្វថ្ងៃនឹងចូលចត្តិញ៉ាំម្ហូបអាហារអីដែលខ្លាចចូលចិត្តជាងគេបង?
ខៈចូលចិត្តសម្លរម្ហូរ។
កៈចូលចិត្តសម្លេរម្ហូរចឹងនែបងនែអត់មានជញ្ជាំប្រហុក?
ខៈជញ្ជាំដែលនឹងតែយូរខ្ញុំនឹងបានជញ្ជាំម្តង។
កៈចឹងអានឹងមិនបានសូវនឹងចំណូនទេបងតែបើសម្លរឬរនេងបានឧសារទិចបងនែ?
ខៈឧសារទិចខ្ញុំនឹងហូបអត់កើតសាច់អីនឹងដល់ឥឡូវនឹង?
កៈចាំនឹងហើយបានតែបន្តែនឹងទិចបងនែ?
ខៈចាំ!
កៈចាំចឹងទាក់ទង់ទៅនឹងបញ្ហាបុណ្យទានទិចបងដូចជាចូលឆ្នាំខ្មែរយើងអីនឹងបងចាំតើកាលពីក្មេងបងធ្លាប់មានបានសប្បាយចិត្តជាមួយនឹងកមវិធីជាមួយល្បែងប្រជាប្រពៃណីដូចបោះឈូងទាញ់ទ្រព្រ៉ៃដែលមានខ្លះទេបង?
ខៈអីពីក្មេងៗនឹងខ្ញុំលេង លេងបោះឈូងលេងបោះអង្គញ។
កៈសប្បាយទេបង?
ខៈសប្បាយណាស់កាលនៅពីក្មេង។
កៈចាំ!
ខៈឥឡូវនឹងលេងលែងកើតហើយឥឡូវនឹង។
កៈចាំៗចឹងសំរាប់បងផ្តាល់តើបងដែលបានចង់ចាំបទចំរៀនណាដែលបងបានរៀនច្រៀងតាំងពីតូចរហូតដល់ធំរហូតដល់សព្វថ្ងៃនឹង?
ខៈអត់ទេ។
កៈអត់ដែលបានចេះច្រៀនអីទេបងកាលនឹងអត់ទេបងនែ?
ខៈអត់ដែលទេ។
កៈអត់ទេបង?
ខៈកាលមុននឹងខ្ញុំនឹងបានចេះតែឥឡូវនឹងខ្ញុំនាមទុងដៃជើងអស់ហើយ។
កៈកូនបានធំអស់ហើយ?
ខៈឈប់លេង។
កៈឈប់ចង់សប្បាយអស់ហើយបង?
ខៈឈប់ចង់សប្បាយអស់ហើយឥឡូវនឹង។
កៈតើមានអារម្មណ៍បើមានកូនហើយនឹង?
ខៈខ្ញុំឥឡូវនឹងបានគិតតែអោយកូនខ្ញុំនឹងបានរៀនអោយបានខ្ពង់ខ្ពស់នឹងគេ។
កៈចាំហើយដូចជាបើសិនជាអាចអោយកូនបានរៀនជ្រៅជ្រះអីចឹងនែបងនែ?
ខៈចាំ!
កៈហើយនឹងបានលែងគិតគូរលេងសប្បាយខ្លួនឯង
តើបងអាចប្រាប់ខ្ញុំបានទេថានៅក្នុងក្រុមគ្រួសាររបស់បងទាំងកូនជំនាន់ក្រោយបងក្មួយៗឬមួយក៏របស់បងតើមានអ្នកណាដែលបានចេះលេងភ្លេងឧបករណ៍?
ខៈអត់ទាន់ចេះផងនឹងៗ។
កៈអត់មានអ្នកណាចេះទេបងនែ?
ខៈមានតែបងខ្ញុំមួយគាត់នៅកំពុងចាមនឹងចេះបងគេ។
កៈគាត់ជាអ្នកភ្លេងអីគេដែលបង?

ខះភ្លេងខ្មែរពីដើមចូលចិត្តណាស់ភ្លេង។
កះតែគាត់នឹងបានប្រើជាអាជីមជាអ្នកភ្លេងនឹងបានរកលុយចឹញ្ចឹមខ្លួនទេបង?
ខះអត់ផង។
កះតែគាត់នឹងបានគ្រាន់តែចូលចិត្តលេងនែបងនែ?
ខះគាត់គ្រាន់តែគាត់នឹងបានចូលចិត្តលេងគាត់នឹងបានច្រៀងលេងអីនឹងពីដើមនឹង។
កះអូច៉ា?
ខះឥឡវគាត់នៅតែចេញលេងដែល។
កះច៉ាបើសិនគាត់នឹងអាចប្រើជាអាជីមនឹងអត់ទេបងនែ?
ខះអត់ទេ។
កះតើផ្ទះបងនឹងមានលណ្ឌះមិចដែលកាលបងដែលបងបានរស់នៅជាមួយនឹងម្តាយឱពុកបងរហូតដល់សព្វថ្ងៃនឹង?
ខះផ្ទះខ្ញុំនឹងតូចនឹងផ្ទះទទឹង៥បណ្តាយ៦ទល់ឥឡវនឹងនៅស្រុក។
កះ ដំបូលធ្វើអំពីអ្វីទៅបង?
ខះ ដំបូលស្លឹកធម្មតារផ្ទះស្លឹកធម្មតារ។
កះ ចង់និយាយថាដំបូលដំបូលស្លឹក?
ខះ ជញ្ជែងស្លឹកដំបូលស្លឹក។
កះ ច៉ាជញ្ជែងស្លឹកដំបូលស្លឹក?
ខះ អានៀបអាសី។
កះ
ច៉ាអានៀបអាសីច៉ាកាលនឹងបងកើតមកបងយើញផ្ទះនឹងតែម្តងឬក៏បងបានជួយធ្វើដែលកាលនឹង?
ខះ
អត់ទេគាត់នឹងបានកើតខ្ញុំបានពេញនេះហើយនឹងបានគាត់នឹងបានធ្វើបេះស្លឹកដេរចាក់រែកដីចាក់ចូលក្រោមផ្ទះនឹងទុបតែធ្វើផ្ទះចាស់នោះពុកអស់ហើយ។
កះ ច៉ាដល់ពេលនេះតុបតែធ្វើថ្មីបងណាស់?
ខះ ច៉ា!
កះ ច៉ាផ្ទះស្លឹកដ៉ដែលបងណាស់?
ខះ ច៉ា!
កះ ច៉ាសំរាប់បងផ្ទាល់ផ្ទះនឹងបងធ្វើខ្លួនឯងឬមួយក៏បងជួរគេធ្វើដែរបង?
ខះ បងគាត់ជួយធ្វើគ្មានជួលគេធ្វើទេ។
កះ បានបងធ្វើខ្លួនឯងបងណាស់?
ខះ បងៗគាត់ជួយធ្វើអត់មានជួលគេធ្វើអស់មួយកាក់ទេ។
កះ ច៉ាចឹងតើសំភារះដែរបងធ្វើនឹងមានគ្រឿងសំភារះអ្វីខ្លះដែរបង?
ខះ
មានអីមានតែដែកគោអាញ្ចុំដំដាក់ៗទៅនឹងមានតារគេលាក់ក្បារសសរតិចនឹង។
កះ ច៉ាហើយនឹងដូចជាអាណាដែលនឹងបង?
ខះ ច៉ា!
កះ អត់មានដូចឥឡវមានម៉ូទ័រកាត់ម៉ូទ័រអីទៅបង?
ខះ ច៉ាអត់មានម៉ូទ័រកាត់អីដូចឥលូវនឹងណា។
កះ ច៉ាអ្នកជិតខាងអត់មានអ្នកនាគេជួយសោះម៉ងបង?
ខះ ជួយដែលគេជួយមួយផ្លែតៗនឹងគេទៅផ្ទះរិញទៅ។
កះ ច៉ាយើងស្តីគេបានត្រឹមតែជួយលើកអីទិចនឹងទៅ?
ខះ ច៉ា!
កះ
ច៉ាចឹងតើបងមានបានបន្តរៀនអ្វីខ្លះពីគ្រួសាររបស់បងដូចជាសិប្បកម្មដំប្បាញសិប្បកម្មកូរស្ពរត្នោត
សិប្បកម្មចាក់ស្លឹកអីចឹងទៅបង?
ខះ
អត់ចេះតែខ្ញុំចេះតែប្រក់ស្បោដេរស្លឹកដំប្បាញខ្ញុំអត់ចេះទេបើខ្ញុំតាំងពីតូចមកខ្ញុំលំបាករហូត។

ក៖ ចាំចឹងបងចេះតែច្រង់ស្បោធ្វើផ្ទះខ្លួនឯងតារពិននឹងទេ?
ខ៖ ចាំ!
ក៖ បើដើរលក់អ្វីជាអាជីបអត់ទេបងណាស់?
ខ៖ ខ្ញុំកាលមុនខ្ញុំដើរលក់ដែលខ្ញុំដើរលក់អួសលក់ពួតអីនឹងទៅ។
ក៖ ចាំឥឡូវនឹងឈប់អស់ហើយបងនៅផ្ទះស្អាត?
ខ៖ នៅផ្ទះឥឡូវនឹងវាឈឺពោកឥឡូវនឹង។
ក៖
ចាំបញ្ហាដែលបងមាននៅក្នុងជីវិត្តមិនអាចបំផ្លេចបានដែលឈឺចាប់មានអ្វីខ្លះដែរបង?
ខ៖ ឆ្នែតហើយតែឥឡូវមានប្តីទៅវាមិនសូវពិបាកទេយើងទុបតែធ្វើការបាន៤ ៥ខែនឹងអោយឈប់។
ក៖ ចាំដោយសារប្តីបងជាអ្នករ៉ាប់រងអស់ហើយបងណាស់?
ខ៖ ចាំ!
ក៖
ចាំតើបងមានបទពិសោតន៍ណាដែលបងបានសប្បាយចិត្តដូចជាពេលបុណ្យទានការបងឃួនសប្បាយចិត្តខ្លះទេបង?
ខ៖ សប្បាយចិត្តការពេលបងចូលរ្នាំការក្មួយផងខ្ញុំអត់ចេះរាំនឹងគេផង។
ក៖ចាំបងនៅអង្គុញមើលគេបង?
ខ៖ អង្គុញមើលការក្មួយរាំ។
ក៖
ចាំចឹងតាំងពីតូចរហូតមកដល់ធំតើបងមានពងប្រាថ្នាថាចង់ធ្វើការងារអ្វីដែលធំដំសំរាប់មានការងារផ្សេងៗទៀតដូចជារៀនខាងគ្រូពេទ្យដូចជាពេលបានរៀនណាស់ឧទាហន៍ថារៀនបានខ្លាចជាគ្រូពេទ្យគ្រូបង្រៀនសិប្បកម្មធ្វើអ្វីមួយដែលជាក់លាក់ច្បាស់លាស់ណាស់តើបងមានបំណងពងប្រាថ្នាចង់ខ្លាចជាចឹងទេបង?
ខ៖
ខ្ញុំមិនដែលពងប្រាថ្នាទេម៉ែខ្ញុំឈឺពោកដល់ពេលចឹងម៉ែគាត់អោយធ្វើស្រែចិញ្ចឹមម៉ែការពិននឹងដល់ពេលម៉ែខ្ញុំផុតទោដើរបានឆ្ងាយដែលដើរដល់ភ្នំដង់រែកខ្ញុំដើរទៅភ្នំដង់រែកអស់រយៈពេល៣ឆ្នាំទៅនៅនឹងបាន៣ឆ្នាំបានខ្ញុំមកនៅនឹងបាន១ឆ្នាំ។
ក៖ បងនៅនឹងតើបងធ្វើអ្វីបងនៅភ្នំដង់រែកនឹងបង?
ខ៖ មានធ្វើអីចាប់អាគុញអោយគេឥឡូវខ្ញុំលែងហើយខ្ញុំឈប់ហើយ។
ក៖
ចាំចឹងជាចុងក្រោយតើបងមានអ្វីដែលត្រូវផ្តាំផ្ញើទៅកូនចៅជំនាន់ក្រោយអោយគេបានដឹងអំពីគោរបំណងរបស់បងខំប្រឹងរៀនអោយកូនបងខំប្រឹងរៀនសូត្រ?
ខ៖
ខ្ញុំមានអ្វីទេខ្ញុំមានតែអោយកូនចៅខំប្រឹងរៀនសូត្រកុំអោយលំបាកដូចជាខ្ញុំចឹងណាស់អោយវាខំប្រឹងរៀនភាសាខ្មែរផងរៀនភាសាអង់គ្លេសផងអោយវារៀនរាល់ថ្ងៃនឹងអោយវាខំប្រឹងកុំអោយលំបាកដូចម៉ែចឹងណាស់អោយវាតរទៅមុខទៀតអោយមានមុខរបរត្រឹមត្រូវទៅ។
ក៖
ចាំអោយគេចេះប្រើលជីវិត្តគេអោយមានតម្លៃកុំអោយមានការលំបាកដូចជារូបបងចឹងណាស់?
ខ៖ ចាំ!
ក៖ ចាំចឹងបើខាងជៀសវាងតើបងគួរតែអោយជៀសវាងពីអ្វីខ្លះបង?
ខ៖ មិនដឹងអោយជៀសវាងអ្វីទេគ្រានតែកុំអោយវាក្រលំបាកដូចជាខ្ញុំចឹងណាស់។
ក៖
ចាំចឹងគ្រឿងញៀញល្បែងស៊ីសងបងតូចបងធំអីតើបងគួរតែអោយពួកគាត់ជៀសវាងឬក៏កូនចៅជំនាន់ក្រោយចឹងណាស់បង?
ខ៖ ចាំនឹងហើយរឿងនឹងខ្ញុំមិនចូលចិត្តទេខ្ញុំមិនអោយចូលទៅជិតទេ។
ក៖ ចាំអោយពួកគាត់ជៀសវាងណាស់បង?
ខ៖ ចាំអោយជៀសវាងរហូតនឹងបង។
ក៖ ចាំមិត្តភក្តិល្អៗចាប់ជៀបគបមិត្តដែលមិនល្អៗកុំអោយសេពគបណាស់បង?

ខ៖ ចា!
ក៖ ចឹងបងមានការពិននឹងទេបងណាស់?
ខ៖ ចា!
ក៖
ចាចឹងជាចុងក្រោយខ្ញុំសូមអរគុណបងណាស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃសំរាប់ខ្ញុំផ្តាល់នឹងសំរាប់សាលារៀន B Y U
ខ្ញុំហើយជាពិសេសខ្ញុំជូនពរបងឆ្នាំថ្មីខ្ញុំសូមអោយបងមានការរក់ស៊ីមានបានមានសុខភាពល្អនៅក្នុងគ្រួសារបងហើយសូមអោយកូនៗរបស់បងនៅពេលដែលបានឮសំឡេងរបស់បងសូមអោយពួកគេខំប្រឹងរៀនសូត្រហើយនឹងធ្វើដំឡាបតាមនៅអ្វីៗដែលចាស់ទុំគេបានបង្រៀនបានផ្តែផ្តៅចឹងណាស់បងណាស់?
ខ៖ ចា!
ក៖
ចាខ្ញុំសូមអរគុណបងចាខ្ញុំសូមជំរាបលាបងសូមអោយបងមានសុខល់ភាពល្អណាស់បង។